# I. ទីស្ដីការគណៈរដ្ឋមន្ត្រី

## ១. អនុក្រឹត្យ

*ភ្នំពេញ ថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣*

### អនុក្រឹត្យលេខ ១០ អនក្រ

### រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណា ព្រះបាទនរោត្តម សីហនុវរ្ម័ន ព្រះចៅក្រុងកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- យោងតាមការចាំបាច់

### សំរេច

**មាត្រា ១ :** សាលាជាតិរដ្ឋបាល ត្រូវបានប្ដូរឈ្មោះ ជាសាលាភូមិន្ទរដ្ឋបាល ដែលស្ថិតក្រោមការគ្រប់គ្រងផ្ទាល់ របស់ទីស្ដីការគណៈរដ្ឋមន្ត្រី ។

**មាត្រា ២ :** ភារកិច្ចចនាសម្ព័ន្ធរបស់សាលាភូមិន្ទរដ្ឋបាល ត្រូវកំណត់ឡើងវិញដោយបានសម្រេច ។

**មាត្រា ៣ :** បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយពីអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៤ :** សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី បណ្ដារដ្ឋមន្ត្រី នៃគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ អនុរដ្ឋលេខាធិការ មុខងារសាធារណៈនិងនាយកសាលាភូមិន្ទរដ្ឋបាល មានភារកិច្ចអនុវត្តអនុក្រឹត្យ នេះចាប់ពីថ្ងៃឡាយព្រះហត្ថលេខា និងចុះហត្ថលេខាតទៅ ។

ជ. រាជរដ្ឋាភិបាល

| | |
|---|---|
| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
| ព្រះហស្តលេខា និង ត្រា | ហត្ថលេខា និង ត្រា |
| សម្ដេចក្រុមព្រះ **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

**********